# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់ឯកឧត្តម ម៉ាសាហ៊ុមី គួរូគី
## ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីសម្ពោធបើកអោយប្រើប្រាស់ជាផ្លូវការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ

ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២

សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**

សូមគោរព **ឯកឧត្តម ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន

សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានមកចូលរួមពិធីសម្ពោធបើកអោយប្រើប្រាស់ជាផ្លូវការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ និង ពិធីសំណេះសំណាលជាមួយកម្មករ-បុគ្គលិកក្នុងទិវាពលកម្មអន្តរជាតិលើកទី ១២៦ នៅថ្ងៃនេះ ។

ជាបឋម ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេច និង លោកជំទាវ** អញ្ជើញមកជាអធិបតីក្នុងពិធីនេះ។

កំពង់ផែក្រុងព្រះសីហនុ គឺជាគំរោងនិមិត្តរូបដ៏ឧត្តុង្គឧត្តមមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុននៅប្រទេសកម្ពុជា ។ ចាប់តាំងពីឆ្នាំ ១៩៩៦ មក រដ្ឋាភិបាលជប៉ុនបាន និងកំពុងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួន

ដើម្បីសាងសង់ផែកុងតឺន័រ និង ចំណតពហុបំណង ក៏ដូចជាផ្តល់ជំនួយសហប្រតិបត្តិការបច្ចេកទេសសំរាប់ការគ្រប់គ្រងកំពង់ផែប្រកបដោយប្រសិទ្ធភាព ។

ថ្ងៃនេះ យើងប្រារព្ធពិធីសម្ពោធបញ្ចប់ការសាងសង់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុដែលផ្តល់ហិរញ្ញប្បទានដោយកម្ចីសម្បទានរបស់ជប៉ុនចំនួន ៣,៦កោដិយ៉េន ស្មើនឹងប្រហែល ៤៥ លានដុល្លារ៍អាមេរិក ។

តំបន់សេដ្ឋកិច្ចពិសេសត្រូវបានរំពឹងទុកថានឹងទាក់ទាញការវិនិយោគទុនដោយផ្ទាល់ពីបរទេសដើម្បីផលិត និង នាំចេញផលិតផលកម្មន្តសាល ។ ការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់នៃតំបន់សេដ្ឋកិច្ចពិសេសនេះជាមួយកំពង់ផែក្រុងព្រះសីហនុ គឺជាឧត្តមភាពមួយនៃបណ្តាឧត្តមភាពនានារបស់តំបន់សេដ្ឋកិច្ចពិសេសនេះដោយការកាត់បន្ថយថ្លៃ និង ពេលវេលាសំរាប់ការដឹកជញ្ជូនសំភារៈ និងផលិតផល ។ គុណភាពខ្ពស់នៃហេដ្ឋារចនាសម្ព័ន្ធមានដូចជាបណ្តាញផ្គត់ផ្គង់ទឹកស្អាត និង ប្រពន្ធ័ចំរោះទឹកកខ្វក់ និងប្រពន្ធ័លូបង្ហូរទឹកនៅក្នុងតំបន់ក៏ជាចំណុចទាក់ទាញមួយទៀតនៃតំបន់សេដ្ឋកិច្ចពិសេសនេះ ។

ខ្ញុំបានដឹងថា ក្រុមហ៊ុន Ojitex Harta Packaging Ltd. ជាក្រុមហ៊ុនសាខាមួយរបស់ជប៉ុនផលិតប្រអប់កាតុង បានសំរេចចិត្តរួចហើយដើម្បីធ្វើប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាវិនិយោគិនជាច្រើនទៀត ជាពិសេសវិនិយោគិនមកពីប្រទេសជប៉ុននឹងមកបណ្តាក់ទុននៅតំបន់សេដ្ឋកិច្ចពិសេសនេះ និងរួមចំណែក ដល់ការបង្កើតនូវការងារថ្មីៗ ការធ្វើពិពិធកម្មផលិតកម្មឧស្សាហកម្ម និង ការជំរុញការនាំចេញរបស់កម្ពុជា ។

ការបញ្ចប់ការសាងសង់តំបន់សេដ្ឋកិច្ចពិសេសនេះមិនមែនជាដំណាក់កាលចុងបញ្ចប់នោះទេ ផ្ទុយទៅវិញវាគឺជាការចាប់ផ្តើមគំរោង ។ ខ្ញុំសង្ឃឹមថា អាជ្ញាធរកំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងខិតខំប្រឹងប្រែងដើម្បីលើកស្ទួយតំបន់សេដ្ឋកិច្ចពិសេសនេះអោយវិនិយោគិនដែលមានសក្តានុពលធំៗបានស្គាល់ និង ទាក់ទាញពួកគេអោយមកបណ្តាក់ទុនយ៉ាងឆាប់បំផុតដែលអាចធ្វើទៅបាន ។

ក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃ និងខ្លាំងក្លារបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាមានប្រវត្តិទទួលបាននូវកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នៅក្នុងទស្សវត៍កន្លងមក ហើយ ទោះបីជាវិបត្តិសេដ្ឋកិច្ចសកលនៅឆ្នាំ ២០០៩ ក្តីក៏ពុះពារជំនះបានដែរដើម្បីវិលទៅរកប្រវត្តិជោគជ័យនៃកំណើន ។ មុខមាត់របស់ប្រទេសកម្ពុជាមានការផ្លាស់ប្តូរទាំងស្រុង ពីប្រទេសមួយដែលទទួលរងនូវការលំបាកកាលពីមុននោះទៅ

ជាប្រទេសមួយដែលមានសក្តានុពល និងកាលានុវត្តិភាពដ៏ធំធេង ។ ប្រទេសកម្ពុជាឥឡូវនេះកំពុងទាក់ទាញការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានសកលលោក ថាជាប្រទេសគោលដៅមួយនៃការវិនិយោគទុនដោយផ្ទាល់ពីបរទេស (FDI) ។

ខ្ញុំសូមលើកឧទាហរណ៍មួយពីការវិនិយោគទុនរបស់ជប៉ុន ។ ជាយូរណាស់មកហើយ ការវិនិយោគទុនពីជប៉ុនមកកាន់កម្ពុជានៅតែស្ថិតនៅក្នុងកំរិតទាប ប៉ុន្តែចាប់តាំងពីឆ្នាំ ២០១០ មក យើងមានក្រុមហ៊ុនជប៉ុនកាន់តែច្រើនឡើងមកបណ្តាក់ទុននៅកម្ពុជា ។ នៅឆ្នាំ ២០១០ មានគំរោងវិនិយោគថ្មីរបស់ជប៉ុនចំនួន ៦ ត្រូវបានអនុមតិជាមួយនឹងទឹកប្រាក់វិនិយោគសរុបទាំងអស់ ៣៥ លានដុល្លារអាមេរិក ហើយនៅឆ្នាំ ២០១១ មានគំរោងវិនិយោគថ្មីចំនួន ១៩ ត្រូវបានអនុមតិដែលមានទឹកប្រាក់វិនិយោគទាំងអស់ចំនួន ៧៥ លានដុល្លារអាមេរិក ។ ខ្ញុំរំពឹងថានឹងមានការបណ្តាក់ទុនច្រើនទៀតពីប្រទេសជប៉ុននៅឆ្នាំ ២០១២ នេះ។

ប្រទេសកម្ពុជាជាផ្នែកមួយនៃតំបន់មេគង្គ ហើយការអភិវឌ្ឍន៍តំបន់នេះមានអត្ថន័យសំខាន់ខ្លាំងណាស់ដើម្បីសំរេចអោយបាននូវសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥ ។ ដោយយកចិត្តទុកដាក់ទៅដល់សារសំខាន់នៃការអភិវឌ្ឍន៍របស់បណ្តាប្រទេសនៅតំបន់មេគង្គ រដ្ឋាភិបាលជប៉ុនបានរៀបចំកិច្ចប្រជុំកំពូលជប៉ុន-មេគង្គ កាលពីថ្ងៃទី ២១ មេសា នៅទីក្រុងតូក្យូ ដែល **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានដឹកនាំគណប្រតិភូអញ្ជើញចូលរួម ។

នៅក្នុងឱកាសនោះ រដ្ឋាភិបាលជប៉ុនបានសន្យាផ្តល់ជំនួយចំនួន ៦០០ កោដិយ៉េនប្រាក់ជប៉ុន ស្មើនឹង ៧,៤ កោដិដុល្លារអាមេរិក ជាជំនួយអភិវឌ្ឍន៍ជូនដល់ប្រទេសទាំង ៥ នៅតំបន់មេគង្គចាប់ពីឆ្នាំ ២០១៣ ដល់ ២០១៥ ។ គំរោងហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងទៅនឹងការជំរុញការតភ្ជាប់ និង ការជំរុញពាណិជ្ជកម្ម និង វិនិយោគ គឺជាវិស័យអាទិភាពមួយ នៃបណ្តាវិស័យអាទិភាពនានានៃជំនួយឧបត្ថម្ភរបស់ជប៉ុនសំរាប់បណ្តាប្រទេសនៅក្នុងតំបន់មេគង្គ ។

សំរាប់ប្រទេសកម្ពុជា ប្រទេសជប៉ុននឹងបន្តយកចិត្តទុកដាក់ទៅលើគំរោងអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ដែលចាប់ផ្តើមពីទីក្រុងហូជីមិញឆ្លងកាត់ទីក្រុងភ្នំពេញទៅកាន់ទីក្រុងបាងកក ក៏ដូចជាការអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ រួមទាំងតំបន់សេដ្ឋកិច្ចពិសេសនេះផងដែរក្នុងចំណោមគំរោងអភិវឌ្ឍផ្សេងៗទៀត ។ ខ្ញុំសង្ឃឹមថាកំពង់ផែក្រុងព្រះសីហនុ ដោយរួមជាមួយនឹងតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងបំពេញតួនាទីដ៏មានសារៈសំខាន់ដើម្បីជំរុញពាណិជ្ជកម្ម និង ការវិនិយោគ និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយថាមពលរបស់កម្ពុជា ដែលអាចបង្កើតកាលានុវត្តិភាពការងារសមរម្យដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជនវ័យក្មេងរបស់កម្ពុជា ។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធមិដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកដល់ការបញ្ចប់គំរោងនេះ និងសង្ឃឹមយ៉ាងមុតមាំថាតំបន់សេដ្ឋកិច្ចពិសេសនេះនឹងស្ថិតនៅជានិមិត្តរូបមួយនៃទំនាក់ទំនងដ៏យូរអង្វែងរវាងប្រទេសជប៉ុន និង ព្រះរាជាណាចក្រកម្ពុជា ។

ហើយចុងបញ្ចប់នេះ នៅក្នុងឱកាសទិវាពលកម្មអន្តរជាតិលើកទី ១២៦ ខ្ញុំសូមជូនពរ សូមសម្តេច លោកជំទាវ ឯកឧត្តម ភ្ញៀវកិត្តិយស លោកស្រី និងអ្នកលោកទាំងអស់ទទួលបាននូវសុភមង្គល សុខភាពល្អ និង វិបុលសុខ ។

សូមអរគុណ ។